# ការធ្វើអាជីវកម្មនិងការប្រើប្រាស់ជីកសិកម្ម

*ដោយបណ្ឌិត **ច័ន្ទ សារុន***
*រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ*




## I-សេចក្តីផ្តើម

នៅប្រទេសកម្ពុជាចាប់ផ្តើមមានការប្រើប្រាស់ជីគីមី និង ថ្នាំកសិកម្មនៅទសវត្សរ៍ឆ្នាំ៥០តាមរយៈជំនួយបរទេសនិងការនាំចូលដោយរដ្ឋតាមរយៈក្រុមហ៊ុនជាតិ នីហរ័ណ អាហារ័ណដែលមានតួនាទីគ្រប់គ្រង និងផ្គត់ផ្គង់សម្រាប់ការលក់ចែកចាយនៅក្នុងស្រុក។ ក្រោយថ្ងៃរំដោះ ៧ មករា ឆ្នាំ១៩៧៩ វិស័យកសិកម្មជាតិត្រូវបានស្តារឡើងវិញ ដែលនៅដំណាក់កាលនោះសម្ភារកសិកម្ម ជាពិសេសគ្រាប់ពូជស្រូវ ជីគីមី ថ្នាំកសិកម្ម ត្រូវបាននាំចូលពីបរទេស តាមរយៈជំនួយពីបណ្តាប្រទេសជាមិត្ត និងអង្គការមនុស្សធម៌នានា។

ក្នុងយុគសម័យបច្ចុប្បន្ន ជីកសិកម្មក៏ដូចជាសម្ភារកសិកម្មផ្សេងទៀតត្រូវបានផលិតឡើងតាមបច្ចេកវិជ្ជាទំនើបដែលលាយផ្សំដោយសារធាតុគីមី ឬសារធាតុជីវសាស្ត្រដែលជផលិតផលមានហានិភ័យគ្រោះថ្នាក់ខ្ពស់។ ពិតមែនតែជីកសិកម្មបំពេញមុខងារចម្បងក្នុងការបង្កើនផលិតភាពនិងទិន្នផលទាំងបរិមាណនិងគុណភាពនៃដំណាំនៅក្នុងផលិតកម្មកសិកម្ម ប៉ុន្តែក៏ទាមទារការប្រើប្រាស់តាមក្បួនខ្នាត(បមាណីយ)ត្រឹមត្រូវ និងដោយប្រុងប្រយ័ត្នបំផុតផងដែរ។ដើម្បីបង្កើនផលិតភាពដំណាំចាំបាច់ត្រូវតែមានការដាក់ជីបន្ថែមឲ្យដំណាំ ដើម្បីផ្តល់សារធាតុចិញ្ចឹមស្របតាមតម្រូវការរបស់ដំណាំ និងប្រភេទដី ដោយឈរលើមូលដ្ឋាននៃការគិតគូរថែរក្សាធនធាន និងជីវិតរបស់ដី។ ការប្រើប្រាស់ជីធម្មជាតិដែលអាចរកបាននៅតាមមូលដ្ឋានជាវិធានការដ៏ប្រសើរបំផុត ដោយក្រៅពីអាចផ្តល់ប្រសិទ្ធភាពសេដ្ឋកិច្ច (ចំណេញ) ក្នុងផលិតកម្ម ការប្រើជីធម្មជាតិជាការថែរក្សា និងការលើកកម្ពស់កែលម្អគុណ ភាពដី រក្សាជីវិតដីដែលជាកេរ្តិ៍មរតកតកូនចៅរបស់កសិករគ្រប់រូប។ការប្រើជីគីមីតែឯកឯងក្នុងកម្រិត និងប្រភេទមិនសមស្របដោយប្រាសចាកគោលការណ៍បច្ចេកទេស គឺជាមូលហេតុជំរុញឱ្យមានការខាតបង់សេដ្ឋកិច្ច និងការសឹករិចរិលជីជាតិដីដែលបង្កឡើងពីការសម្លាប់រង្គាលចំពោះអតិសុខុមប្រាណដែលរស់នៅក្នុងដី និងពឹងអាស្រ័យដោយសារធាតុសរីរាង្គ។

ស្ថានភាពបច្ចុប្បន្ននៃផលិតកម្មកសិកម្មនៅក្នុងមូលដ្ឋានមួយចំនួន ការប្រើប្រាស់ជីគីមីបន្ថែមដល់ដំណាំដើម្បីជំរុញផលិតភាព និងបង្កើនទិន្នផលទាំងបរិមាណនិងគុណភាពរបស់ដំណាំនៅតែជាការចាំបាច់នៅឡើយ អាស្រ័យដោយធនធានជីធម្មជាតិរបស់យើងនៅមានកម្រិត។ ប៉ុន្តែការប្រើប្រាស់ជីកសិកម្មដោយងងឹតងងល់ខុសក្បួនខ្នាតបច្ចេកទេស អាចនាំមកនូវគ្រោះថ្នាក់ដល់សុវត្ថិភាពស្បៀង សុខភាពសាធារណៈ និងបរិស្ថាន ព្រមទាំងបង្កើនចំណាយផលិតកម្មខ្ពស់ដែលជារបាំងមួយប្រឈមចំពោះសន្ទុះអភិវឌ្ឍសង្គម សេដ្ឋកិច្ច និងយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាល។ ដូច្នេះ ការគ្រប់គ្រងអាជីវកម្ម និងការប្រើប្រាស់ជីកសិកម្មប្រកបដោយប្រសិទ្ធភាព និងសុវត្ថិភាព មានតួនាទីយ៉ាងសំខាន់ក្នុងការចូលរួមចំណែក ដើម្បីធ្វើឱ្យសម្រេចជោគជ័យនូវគោលនយោបាយអភិវឌ្ឍន៍វិស័យកសិកម្ម ជាពិសេសគោលនយោបាយជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករបស់រាជរដ្ឋាភិបាល។

## II- ស្ថានភាពរួមនៃការគ្រប់គ្រងជីកសិកម្ម

### ១-ក្របខណ្ឌគោលនយោបាយ គតិយុត្តនិងការគ្រប់គ្រង

ក្នុងក្របខណ្ឌគោលនយោបាយ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** តែងបានយកចិត្តទុកដាក់ខ្ពស់ក្នុងការផ្តល់អនុសាសន៍ជាត្រីវិស័យ តម្រង់ទិសលើវិធានការគ្រប់គ្រងនិងត្រួតពិនិត្យគុណភាពជីកសិកម្ម ក៏ដូច

ជាសម្ភារកសិកម្មផ្សេងទៀត ដើម្បីធានាឱ្យកសិករទទួលយកបាននូវការយល់ដឹងពីផលប្រយោជន៍ នៃការប្រើប្រាស់ធាតុចូលទាំងនេះនៅក្នុងផលិតកម្មកសិកម្ម ព្រមទាំងធានាឱ្យកសិករអាចទិញបានយកទៅប្រើប្រាស់ប្រកបដោយគុណភាពនិងសុវត្ថិភាព។



ទន្ទឹមនេះ ការអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាលអំពីសារពើពន្ធ ដោយកំណត់អត្រាពន្ធសូន្យលើសម្ភារកសិកម្មនាំចូល និងការបង្កើតយន្តការព័ត៌មានថ្លៃសម្ភារកសិកម្ម ក្នុងគោលបំណងរក្សាស្ថិរភាពនិងបន្ទាបថ្លៃសម្ភារកសិកម្មក៏ដូចជាបន្ទាបថ្លៃដើមផលិតផលកសិកម្ម ដើម្បីឱ្យកសិករអាចទទួលបាននូវឱកាសប្រកួតប្រជែងទីផ្សារជាពិសេសបង្កើនការនាំចេញកសិផលប្រកបដោយគុណភាព។

បច្ចុប្បន្ននេះ ការផ្គត់ផ្គង់ចែកចាយជីកសិកម្មក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តដោយផ្នែកឯកជន ក្រោមការគ្រប់គ្រងទូទៅរបស់ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ។ រាជរដ្ឋាភិបាលតម្រូវឱ្យការផ្គត់ផ្គង់ចែកចាយជីកសិកម្ម អនុវត្តតាមប្រព័ន្ធស្របច្បាប់មួយតាមរយៈក្រុមហ៊ុននាំចូលឬក្រុមហ៊ុនផលិតក្នុងស្រុក ដែលបានទទួលលិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្មពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ហើយប្រភេទជីកសិកម្មទាំងនោះ ត្រូវបានចុះបញ្ជិកាជាផ្លូវការរួច ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងបានឆ្លងកាត់ការវិភាគសមាសធាតុការសាកល្បងលើទីវាលពិសោធន៍ ចំពោះគុណភាព ព្រមទាំងបានវាយតម្លៃប្រសិទ្ធភាព សុវត្ថិភាព និងហានិភ័យ។ ផលិតផលស្របច្បាប់ទាំងនេះ ត្រូវបានផ្គត់ផ្គង់ចែកចាយឱ្យដល់ដេប៉ូលក់ដុំ លក់រាយដែលទទួលលិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្មលក់ដុំ លក់រាយ ដែលចេញដោយមន្ទីរកសិកម្មរាជធានី-ខេត្ត ក្នុងគោលបំណងឱ្យកសិករទទួលបានសម្ភា រកសិកម្មដែលមានប្រភពដើមនាំចូលស្របច្បាប់ និងលក់នៅក្នុងដេប៉ូស្របច្បាប់ ដែលធានាចំពោះការទិញយកទៅប្រើប្រាស់របស់កសិករ។

ក្របខណ្ឌគតិយុត្តមូលដ្ឋានសម្រាប់ការគ្រប់គ្រងជីកសិកម្មក៏ដូចជាសម្ភារកសិកម្មផ្សេងទៀត ត្រូវបានអនុវត្តតាមអនុក្រឹត្យលេខ ៦៩ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ១៩៩៨ ស្តីពី " **បមាណីយ និងការគ្រប់គ្រងសម្ភារកសិកម្ម** " ព្រមទាំងសារាចរណែនាំ ប្រកាស ប្រកាសរួម និងលិខិតបទដ្ឋានជាច្រើនទៀតដែលកំណត់នូវបែបបទ នីតិវិធី និងបទបញ្ញាដើម្បីជំរុញការអនុវត្តច្បាប់ឱ្យមានប្រសិទ្ធភាព។ មកដល់បច្ចុប្បន្ននេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានស្នើសេចក្តីព្រាងច្បាប់ស្តីពី " **ការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម**" ជូនរាជរដ្ឋាភិបាលដើម្បីពិនិត្យសម្រេច និងដាក់ជូនស្ថាប័នសភាអនុម័ត ក្នុងគោលបំណងបង្កើតក្របខណ្ឌច្បាប់គ្រឹះមួយសម្រាប់ការគ្រប់គ្រងថ្នាំកសិកម្ម និងជីកសិកម្ម ដែលជាផលិតផលងាយរងហានិភ័យខ្ពស់ ក៏ដូចជាឆ្លើយតបចំពោះតម្រូវការខមករណ៍ច្បាប់នៅក្នុងក្របខណ្ឌរួមនៃសុវត្ថិភាពស្បៀងផងដែរ។

## ២- បញ្ហាប្រឈម

មកដល់បច្ចុប្បន្ននេះ ពិតមែនតែក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានជំរុញការអនុវត្តកម្មវិធីផ្សព្វផ្សាយ អប់រំ ការយល់ដឹងដល់អាជីវករជីកសិកម្មទាំងវិធានគតិយុត្ត ព្រមទាំងវិធានបច្ចេកទេសពាក់ព័ន្ធ និងបានជំរុញការធ្វើអធិការកិច្ចអនុវត្តច្បាប់លើការធ្វើអាជីវកម្មជីកសិកម្មនៅតាមរាជធានី-ខេត្តគោលដៅមួយចំនួនដោយបានចាត់វិធានការដាក់ទណ្ឌកម្មលើក្រុមហ៊ុននាំចូលជីកសិកម្ម អាជីវករចែកចាយ និងមូលដ្ឋានអាជីវកម្មខុសច្បាប់ជាច្រើនករណី។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ក្រសួងនៅតែទទួលស្គាល់ថានៅជួបបញ្ហាប្រឈមជាច្រើនទៀតក្នុងការគ្រប់គ្រងការធ្វើអាជីវកម្មជីកសិកម្មដែលមានជាអាទិ៍ដូចខាងក្រោម ៖

១-ជីកសិកម្មមួយចំនួននៅតែនាំចូលពីប្រទេសជិតខាងដោយល្មើសច្បាប់ និងបានចរាចរនៅលើទីផ្សារដោយគ្មានការធានាបមាណីយគុណភាព និងគ្មានស្លាកសញ្ញាព័ត៌មានជាភាសាខ្មែរ ឬមានជាភាសាបរទេសលើសំបកវេចខ្ចប់។ផ្អែកតាមលទ្ធផលអង្កេតរបស់នាយកដ្ឋាននីតិកម្មកសិកម្ម ដែលទ្រទ្រង់ដោយគម្រោង QCAM/JICA-MAFF ឆ្នាំ ២០០៩ កន្លងមកជីគីមីដែលចរាចរលើទីផ្សារ( ខេត្តកណ្តាល )បានបង្ហាញថា ៖ **ជីគីមីដែលបានចុះបញ្ជិកាដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មាន ៣៣% ក្នុងនោះ មានស្លាកព័ត៌មានជាភាសាខ្មែរតែ១៤% ប៉ុណ្ណោះ។**

២-ជីកសិកម្មមួយចំនួនត្រូវបានអាជីវករដែលធ្វើការផ្គត់ផ្គង់ចែកចាយបន្តពីក្រុមហ៊ុននាំចូលឬ អាជីវករលក់ដុំ លក់រាយ

ផ្ទាល់តាមបណ្តាដេប៉ូក្នុងរាជធានី-ខេត្តបានធ្វើការលាយផ្សំក្លែងគុណភាពដូចជា ៖

-យកជីប្រភេទអន់គុណភាពតម្លៃថោក កែច្នៃក្លែងគុណភាពធ្វើជាប្រភេទជី ដែលមានតម្លៃខ្ពស់

-ក្លែងបន្លំឬប្តូរសំបកវេចខ្ចប់ដោយផ្ទេរជីអន់គុណភាពតម្លៃថោកមកដាក់ក្នុងសំបកវេចខ្ចប់ជីដែលមានតម្លៃខ្ពស់

-ក្រុមហ៊ុនមួយចំនួនផលិតសំបកការុងជីរបស់ក្រុមហ៊ុនផ្សេងទៀតដែលមានគុណភាពល្អដោយប្តូរសំបកវេចខ្ចប់ជីរបស់ក្រុមហ៊ុនខ្លួនឯងផ្ទាល់ផង និងលក់ចែកចាយសំបកវេចខ្ចប់ទៅឱ្យអាជីវករលក់ដុំលក់រាយតាមរាជធានីខេត្តផង ដែលបង្កនូវប្រព័ន្ធបទល្មើសមួយជំរុញឱ្យអាជីវករលក់ដុំ លក់រាយ ចេះផលិតជីក្លែងគុណភាពឬក្លែងបន្លំសំបកវេចខ្ចប់។



៣-ជីកសិកម្មមួយចំនួនដែលបានលាយផ្សំក្លែងគុណភាពឬក្លែងបន្លំសំបកវេចខ្ចប់ដោយអាជីវករទុច្ចរិត ត្រូវបានដឹកជញ្ជូនចល័តលក់ឬលក់បណ្តាក់តាមភូមិឃុំដល់កសិករផ្ទាល់ដោយអសីលធម៌បំផុត។

៤-ក្រុមហ៊ុននាំចូលជីកសិកម្មមួយចំនួនដែលបានទទួលលិខិតអនុញ្ញាតឱ្យនាំចូល និងបានចុះបញ្ជិកាប្រភេទជី ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរួចហើយ ប៉ុន្តែនៅពេលនាំចូលជាក់ស្តែងក្រុមហ៊ុនបាននាំចូល ជីដែលអន់គុណភាពជាងនៅពេលស្នើសុំចុះបញ្ជិកា និងជាពិសេសក្រុមហ៊ុននៅតែប្រើសំបកវេចខ្ចប់ដែល មានស្លាកសញ្ញាព័ត៌មានជាភាសាបរទេស ដោយពុំព្រមប្រើគំរូស្លាកសញ្ញាព័ត៌មានជាភាសាខ្មែរដែលក្រសួងបានយល់ព្រមនៅពេលចុះបញ្ជិកាឡើយ។

៥-ជីកសិកម្មមួយចំនួនដែលក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានអនុញ្ញាតស្របច្បាប់ឱ្យចុះបញ្ជិកា និងឱ្យនាំចូលមិនអាចប្រកួតប្រជែងជាមួយផលិតផលក្លែងគុណភាព ឬជីដែលមានប្រភពល្មើសច្បាប់បានឡើយ ដែលជាមូលហេតុធ្វើឱ្យចរន្តល្មើសច្បាប់នៅតែមានប្រៀបជាងអំពើស្របច្បាប់ និងជាបច្ច័យអាក្រក់ធ្វើឲ្យអាជីវករដែលនាំចូល និងផ្គត់ផ្គង់ចែកចាយជីកសិកម្មស្របច្បាប់ជួបនឹងបញ្ហាប្រឈម និងធ្វើឲ្យបាត់បង់ជំនឿលើការអនុវត្តច្បាប់។

៦-រាជរដ្ឋាភិបាលបានផ្តល់គោលនយោបាយអនុគ្រោះពន្ធចំពោះការនាំចូលជីកសិកម្មដើម្បីធានា ស្ថិរភាព ឬកាត់បន្ថយថ្លៃដើមផលិតកសិផលឱ្យនៅជាអប្បបរមាប៉ុន្តែចំពោះមុខកសិករនៅមិនទាន់ទទួលយកបាននូវផលប្រយោជន៍នេះនៅឡើយ ផ្ទុយមកវិញកសិករត្រូវបានចំណាយឬបុលប្រាក់ដើម្បីទិញជីកសិកម្មដែលក្លែងគុណភាព គ្មានប្រសិទ្ធភាព និងមិនអាចយល់បានលើសេចក្តីណែនាំប្រើប្រាស់ជាភាសាបរទេស នៅលើស្លាកព័ត៌មាននៃសំបកវេចខ្ចប់របស់ផលិតផលដែលហូរចូលពីប្រភពល្មើសច្បាប់។

៧-ការអប់រំផ្សព្វផ្សាយការយល់ដឹងចំពោះអាជីវករលក់ដូរក៏ដូចជាចំពោះកសិករដែលប្រើប្រាស់ជីកសិកម្ម ត្រូវបានអនុវត្តនិងបង្កើនសកម្មភាពជារៀងរាល់ឆ្នាំ ប៉ុន្តែការទទួលយកចំណេះដឹងពីការអប់រំដល់អាជីវករនិងកសិករនៅមានកម្រិតជាពិសេសការកែប្រែទម្លាប់ ឬប្រពៃណីរបស់អាជីវករ និងកសិករ គឺជាការលំបាក និងទាមទារពេលវេលា(តារាងទី ១ និងទី ២)។



៨-សមត្ថភាពរបស់អង្គភាព និងមន្ត្រីមានសមត្ថកិច្ចនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងការគ្រប់គ្រង ការត្រួតពិនិត្យ និងការអនុវត្តច្បាប់ចំពោះសកម្មភាពអាជីវកម្មជីកសិកម្មបច្ចុប្បន្ន ក៏នៅមានកម្រិតទាំងធនធានមនុស្សហេដ្ឋារចនាសម្ព័ន្ធបច្ចេកទេស ក៏ដូចជាមូលដ្ឋានច្បាប់រឹងមាំដែលអាចគ្រប់គ្រងលើស្ថានភាពអវិជ្ជមាន ខាងលើឱ្យមានប្រសិទ្ធភាពនៅឡើយ។ ដោយឡែកការចូលរួមនិងកិច្ចសហការពីសំណាក់អាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធក្នុងការអនុវត្តច្បាប់ចំពោះបទល្មើសនៅមានកម្រិត និងមិនទាន់ឆ្លើយតប

បានប្រសិទ្ធភាព ចំពោះស្ថានភាព បទល្មើសខាងលើនៅ ឡើយ ( តារាងទី ៣ )។

តារាងទី ១ ៖ លទ្ធផលសកម្មភាពអប់រំផ្សព្វផ្សាយការយល់ដឹងដល់អាជីវករលក់ដូរសម្ភារកសិកម្ម ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

| ឆ្នាំអនុវត្ត | លទ្ធផលសកម្មភាព | |
|---|---|---|
| | ចំនួនលើក | អ្នកចូលរួម |
| ២០០៧ | ១៥០ | ១.៦៥៤ |
| ២០០៨ | ២៨៣ | ៤.៧៦៤ |
| ២០០៩ | ៥២៤ | ១១.០១៥ |
| ២០១០ | ៦៣៨ | ១២.៩៩៤ |
| សរុប | ១.៥៩៥ | ៣០.៤២៧ |




តារាងទី ២ ៖ លទ្ធផលសកម្មភាពបណ្តុះបណ្តាលរបស់កម្មវិធី IPM ជាតិ ឆ្នាំ ១៩៩៣ - ២០០៩

| លទ្ធផលសកម្មភាព | លទ្ធផលសរុប | ផ្សេងៗ |
|---|---|---|
| បណ្តុះបណ្តាលកសិករ | ១៥២.៤៨៥ ( ស្រី ៦៤.១៦៧នាក់ ស្មើ ៤២.០៨%) | សរុប ១៥៩.២៣៩ នាក់ (ស្រី ៦៧.២០៥នាក់ ស្មើ ៤២.២០%) |
| បណ្តុះបណ្តាលគ្រូនិងសិស្ស | ៦.៧៥៤ (ស្រី ៣.០៣៨នាក់ ស្មើ ៤៤.៩៨%) | |
| ការសន្សំនិងប្រើប្រាស់ជីកំប៉ុស្ត៍ | ៧.២៥០ កន្លែង (៧.២៥០គ្រួសារ) | |
| ការធ្វើស្រែបង្ហាញ | ២.១៩០ កន្លែង (៥.៣០០គ្រួសារ) | |
| ការអនុវត្ត ប.រ.ស | ៥៨.២៩០ ហិកតា (១០៤.៧៥០ គ្រួសារ នៅក្នុង ៤២៦១ ភូមិ ៧៩៦ ឃុំ ១៣៤ ស្រុក) | |

តារាងទី ៣ ៖ លទ្ធផលសកម្មភាពអនុវត្តច្បាប់ក្នុងការធ្វើអាជីវកម្មសម្ភារកសិកម្ម

| **ឆ្នាំអនុវត្ត** | **លទ្ធផលសកម្មភាពត្រួតពិនិត្យ** | | | | | |
|---|---|---|---|---|---|---|
| | **ការនាំចូល** | **ដេប៉ូលក់ដុំ លក់រាយ** | **វិធានចំពោះបទល្មើស** | | | |
| | | | ចេញលិខិតព្រមាន | កិច្ចសន្យាកែតម្រូវ | បញ្ជូនទៅតុលាការ | វត្ថុតាង |
| ២០០៦ | ១៧ ក្រុមហ៊ុន | ២១ រាជធានី ខេត្ត | ៥ករណី-ដេប៉ូ | - | - | - |
| ២០០៧ | ១១ ក្រុមហ៊ុន | ១៣ រាជធានី ខេត្ត | - | - | ៥ ករណី | ជីក្លែងគុណភាព ៦៤ បាវ |
| ២០០៨ | ២២ ក្រុមហ៊ុន | ៣៥០ ដេប៉ូ | ៥ករណី-ក្រុមហ៊ុន<br>៤ករណី-ដេប៉ូ | ៥៤ ករណី-ដេប៉ូ | ១ ករណី | -ជីក្លែងគុណភាព ១១០ បាវ<br>-សំបកបាវក្លែង ៦៧៥ |
| ២០០៩ | ៥២ ក្រុមហ៊ុន | ១.២៨៦ ដេប៉ូ | ១២ ករណី-ក្រុមហ៊ុន<br>២៧ករណី-ដេប៉ូ | ៣១៥ ករណី-ក្រុមហ៊ុន<br>៣១៥ ករណី-ដេប៉ូ | ៣ ករណី | - |
| ២០១០ | ៩០ ក្រុមហ៊ុន | ១.៧២៦ ដេប៉ូ | ១៧ ករណី-ក្រុមហ៊ុន | ១២ ករណី-ក្រុមហ៊ុន<br>៣៥០ ករណី-ដេប៉ូ | ៣ ករណី | -គ្រាប់ពូជពោតក្លែងគុណភាព ៣៣៦គ.ក្រ<br>-ជីក្លែងគុណភាព ៥៩ បាវ<br>-សំបកបាវក្លែង ១៥<br>-ម៉ាស៊ីនដេរមាត់បាវ ៥ គ្រឿង<br>-រថយន្ត ១ គ្រឿង<br>-បសុឱសថ ៣៥៨ កេស<br>-អាហារបំប៉នសត្វ ៦ កេស |

III-**អនុសាសន៍**

**ក-ចំពោះអាជីវករជីកសិកម្ម**

ដើម្បីចូលរួមលើកកម្ពស់ការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យកសិកម្ម គោលនយោបាយជម្រុញផលិតកម្មស្រូវ និងការការនាំចេញអង្ករបស់រាជរដ្ឋាភិបាល ឱ្យសម្រេចបានជោគជ័យ អាជីវករសម្ភារកសិកម្ម រួមមានអ្នកនាំចូល នាំចេញ អ្នកផលិត អ្នកផ្គត់ផ្គង់ចែកចាយ អ្នកផ្គត់ផ្គង់ចែកចាយបន្ត អ្នកលក់ដុំ លក់រាយត្រូវអនុវត្តកាតព្វកិច្ចសំខាន់ៗដូចខាងក្រោម៖

១-ត្រូវមានភាពស្មោះត្រង់ ចេះរក្សាកេរ្តិ៍ឈ្មោះ និងមានសីលធម៌ក្នុងមុខរបររបស់ខ្លួន ដោយមិនត្រូវប្រព្រឹត្តអំពើក្លែងបន្លំគុណភាព កែច្នៃផលិតផលខុសពីគុណភាពដើម ឬក្លែងបន្លំសំបកវេចខ្ចប់ និងត្រូវចៀសវាងការទិញចូលសម្រាប់លក់នូវជីឬសម្ភារកសិកម្មដែលរត់ពន្ធ ឬលួចលាក់នាំចូលពីប្រទេសជិតខាង ឬមានប្រភពចេញពីអំពើល្មើសច្បាប់ផ្សេងទៀត។

២-ត្រូវគោរព និងអនុវត្តរាល់នីតិវិធី បទបញ្ជា និងសេចក្តីណែនាំរបស់ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ដោយត្រូវសហការល្អជាមួយអង្គភាពកសិកម្មមានសមត្ថកិច្ចក្នុងការគ្រប់គ្រងសកម្មភាពអាជីវកម្ម ចូលរួមតាមដាន និងត្រូវផ្តល់ព័ត៌មានអំពីបទល្មើសក្លែងបន្លំគុណភាព ក្លែងបន្លំសំបកវេចខ្ចប់ ក្លែងបន្លំពាណិជ្ជសញ្ញាផលិតផលជីកសិកម្មនៅក្នុងមូលដ្ឋានរបស់ខ្លួនដល់មន្ត្រីមានសមត្ថកិច្ច ដើម្បីចាត់វិធានការអនុវត្តច្បាប់។

៣-អាជីវករលក់ដុំ លក់រាយឬសាខាផ្គត់ផ្គង់ចែកចាយជីកសិកម្មទាំងអស់នៅតាមបណ្តារាជធានី-ខេត្ត ត្រូវមានកាតព្វកិច្ចឆ្លងកាត់វគ្គអប់រំសមត្ថភាពវិជ្ជាជីវៈ ស្តីពីនីតិវិធី និងបច្ចេកទេស " **ការដាក់តាំងលក់ល្អ** " ក្នុងការធ្វើអាជីវកម្មរបស់ខ្លួនដែលជាបុរេលក្ខខ័ណ្ឌក្នុងការស្នើសុំលិខិតអនុញ្ញាតធ្វើអាជីវកម្មលក់ដុំលក់រាយជីកសិកម្ម នៅក្នុងមូលដ្ឋានរបស់ខ្លួន។

៤-អាជីវករលក់ដុំ លក់រាយជីកសិកម្មគ្រប់រូបត្រូវមានលិខិតអនុញ្ញាតធ្វើអាជីវកម្មលក់ដុំ លក់រាយ ដែលចេញដោយមន្ទីរកសិកម្មរាជធានីខេត្តសាមី និងត្រូវភ្ជាប់បញ្ជីផលិតផលជីកសិកម្មដែលខ្លួនស្នើសុំលក់ដូរ និងបញ្ជីឈ្មោះក្រុមហ៊ុនដែលផ្គត់ផ្គង់ចែកចាយផលិតផលទាំងនេះឱ្យដេប៉ូលក់ដូររបស់ខ្លួន ដើម្បីធានាភាពស្របច្បាប់នៃប្រភព ជីកសិកម្ម ព្រមទាំងត្រូវអនុវត្តកាតព្វកិច្ចផ្សេងទៀតដែលកំណត់ដោយបទដ្ឋានគតិយុត្ត។

៥-អាជីវករដែលផ្គត់ផ្គង់ចែកចាយបន្តជីកសិកម្មពីក្រុមហ៊ុននាំចូលដល់បណ្តាដេប៉ូលក់ដុំ លក់រាយ ក្នុងរាជធានី-ខេត្តទូទាំងប្រទេស ត្រូវមានលិខិតអនុញ្ញាតធ្វើអាជីវកម្មផ្គត់ផ្គង់ចែកចាយជីកសិកម្ម ដែលចេញដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងត្រូវមានកិច្ចសន្យាធ្វើជាអ្នកផ្គត់ផ្គង់ចែកចាយរបស់ក្រុមហ៊ុន ព្រមទាំងភ្ជាប់បញ្ជីឈ្មោះដេប៉ូឬសាខាលក់ដុំលក់រាយតាមបណ្តារាជធានីខេត្ត ដែលទទួលយកការផ្គត់ផ្គង់របស់ខ្លួន និងត្រូវទទួលខុសត្រូវរួមចំពោះមុខច្បាប់ជាមួយក្រុមហ៊ុននាំចូល និងអាជីវករលក់ដុំ លក់រាយជីកសិកម្មក្នុងខ្សែចង្វាក់ពាណិជ្ជកម្មរបស់ខ្លួន។

៦-បណ្តាសាខាផ្គត់ផ្គង់ចែកចាយនិងអាជីវករលក់ដុំលក់រាយជីកសិកម្ម ត្រូវទិញចូលសម្រាប់លក់តែជីកសិកម្មណា ដែលមានប្រភពស្របច្បាប់តាមប្រព័ន្ធខ្សែចង្វាក់នាំចូល ឬផលិតដោយក្រុមហ៊ុនដែលក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានផ្តល់លិខិតអនុញ្ញាតនិងបានចុះបញ្ជិកាផលិតផលរួច និងត្រូវមានស្លាកសញ្ញាព័ត៌មានជាភាសាខ្មែរនៅលើសំបកវេចខ្ចប់ដែលមានលេខបញ្ជិការបស់ក្រសួងសម្គាល់ជាចាំបាច់។ ផលិតផលស្របច្បាប់ទាំងនេះត្រូវបានផ្គត់ផ្គង់ចែកចាយឱ្យដល់ដេប៉ូលក់ដុំ លក់រាយ ដែលទទួលលិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្មលក់ដុំ លក់រាយចេញដោយមន្ទីរកសិកម្ម រាជធានី-ខេត្ត ដើម្បីឱ្យកសិករអាចទទួលបាននូវជីកសិកម្មដែលមានប្រភពដើមស្របច្បាប់ និងលក់នៅដេប៉ូស្របច្បាប់ ព្រមទាំងធានានូវគុណភាពប្រសិទ្ធភាពចំពោះការទិញយកទៅប្រើប្រាស់។

៧-ត្រូវចាត់ទុកថា " កសិករគឺជាដៃគូអតិថិជនដ៏ល្អរបស់អាជីវករ ដោយអាជីវករត្រូវលក់តែជីកសិកម្មដែលមានគុណភាពល្អ និងមានសុវត្ថិភាពក្នុងការប្រើប្រាស់ដោយត្រូវចេះពន្យល់ដល់កសិករ អំពីរបៀបប្រើប្រាស់តាមប្រភេទដំណាំ និងប្រភេទដីស្របតាមស្លាកសញ្ញាព័ត៌មាននៅលើសំបកវេចខ្ចប់ដែលក្រសួងបានយល់ព្រមនៅពេលចុះបញ្ជិកា ដើម្បីកសិករយកទៅប្រើប្រាស់ចុងក្រោយនៅក្នុងផលិតកម្មកសិកម្ម ឱ្យទទួលបានផលប្រយោជន៍ឈ្នះឈ្នះទាំងអស់គ្នា និងត្រូវរួមគ្នាធ្វើឱ្យគោលនយោបាយរបស់រាជរដ្ឋាភិបាល ក្នុងការជម្រុញផលិតកម្មស្រូវ និងការនាំចេញអង្ករទទួលបានជោគជ័យ។

**ខ-ចំពោះអ្នកប្រើប្រាស់**

កសិករដែលជាអ្នកប្រើប្រាស់ចុងក្រោយនូវជីកសិកម្ម ក៏ដូចជាសម្ភារកសិកម្មផ្សេងទៀត ត្រូវស្វែងយល់ និងត្រូវមានការយល់ដឹងដូចខាងក្រោម ៖



១-មុននឹងសម្រេចចិត្តទិញជីកសិកម្មយកមកប្រើប្រាស់ ត្រូវពិនិត្យឱ្យអស់លទ្ធភាពលើការប្រើប្រាស់ធនធាន ដែលអាច

ប្រមូលយកទៅធ្វើជាជីធម្មជាតិបានដែលមាននៅក្នុងមូលដ្ឋាន។ ត្រូវចងចាំថា ការចំណាយពេលក្នុងការសន្សំជីធម្មជាតិ អាចបង្កើនប្រាក់ចំណេញក្នុងផលិតកម្ម អាចធ្វើឱ្យភូមិដ្ឋានស្អាត និងពិសេសអាចរក្សាគុណភាពដីកសិកម្ម ដែលជាកេរ្តិ៍មរតកសម្រាប់កូនចៅជំនាន់ក្រោយ។ ករណីណាក៏ដោយមិនត្រូវសម្រេចចិត្តប្រើជីគីមី ដោយមិនបានប្រើជីធម្មជាតិសោះនោះឡើយ។

២-ត្រូវជ្រើសរើសទិញតែជីកសិកម្ម ដែលមានប្រភពស្របច្បាប់ធានាគុណភាពច្បាស់លាស់ និងអាចទុកចិត្តបានដោយត្រូវទិញជីកសិកម្មនៅដេប៉ូចែកចាយដែលមានដាក់តាំងបង្ហាញសម្គាល់នៅក្នុងដេប៉ូនូវលិខិតអនុញ្ញាតធ្វើអាជីវកម្ម លក់ដុំលក់រាយ ចេញដោយមន្ទីរកសិកម្មរាជធានី-ខេត្តសាមី។

៣-ត្រូវជ្រើសរើសទិញជីកសិកម្មដែលមានសំបកវេចខ្ចប់ត្រឹមត្រូវមានស្លាកសញ្ញាព័ត៌មានជាភាសាខ្មែរ ដែលបង្ហាញអំពីប្រភេទជី សារធាតុចិញ្ចឹម ប្រភពដើមផលិត នាំចូល និងផ្គត់ផ្គង់ចែកចាយ របៀបប្រើប្រាស់តាមប្រភេទដំណាំ និងជាពិសេសត្រូវពិនិត្យមើលលេខបញ្ជិកាដែលក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានផ្តល់ឱ្យ។



៤-ត្រូវជៀសវាងទិញជីកសិកម្មដែលសំបកវេចខ្ចប់មានស្លាកសញ្ញាព័ត៌មានជាភាសាបរទេសដែលមិនអាចយល់បានពីប្រភេទគុណភាព និងរបៀបប្រើប្រាស់របស់ជី។

៥-មិនត្រូវទិញជីកសិកម្មទាំងឡាយណា ដែលបានដឹកជញ្ជូនលក់ចែកចាយឬលក់បណ្តាក់ដល់លំនៅឋានកសិករ ផ្ទាល់ដែលជាប្រភេទជីគ្មានប្រភពច្បាស់លាស់ គ្មានការធានាគុណភាព ឬជាជីកសិកម្មដែលក្លែងបន្លំគុណភាព និងមានប្រភពល្មើសច្បាប់។

៦-ការធ្វើខ្លួនឱ្យក្លាយទៅជាក្រុមហ៊ុនគំរូ អ្នកចែកចាយគំរូ និងអ្នកលក់បន្តគំរូ ក្នុងការជួញដូរជីគីមី និងសម្ភារកសិកម្មដែលជាទំនិញមានសក្តានុពលហានិភ័យ អាចនឹងប៉ះពាល់ដល់សេដ្ឋកិច្ច និងធនធានធម្មជាតិ ពិតជាសកម្មភាពចូលរួមក្នុងការអភិវឌ្ឍន៍វិស័យកសិកម្ម និងខឿនសេដ្ឋកិច្ច ដែលនឹងត្រូវទទួលបាននូវការជ្រោមជ្រែង និងលើកទឹកចិត្ត។ ក្រៅពីភាពស្មោះត្រង់នោះ ក្រុមហ៊ុនត្រូវពង្រឹងបណ្តាញតាមដាន និងសហការទប់ស្កាត់រាល់សកម្មភាពក្លែងបន្លំដើម្បីការពារពាណិជ្ជសញ្ញារបស់ខ្លួន និងត្រូវចូលរួមណែនាំដល់អ្នកប្រើប្រាស់ ដើម្បីទទួលបានប្រសិទ្ធភាព សុវត្ថិភាព និងពិសេស ប្រសិទ្ធភាពសេដ្ឋកិច្ចក្នុងការប្រើប្រាស់។

## VI-**សេចក្តីសន្និដ្ឋាន**

ចំពោះមុខ ពិតមែនតែការប្រើប្រាស់ជីកសិកម្ម ក៏ដូចជាសម្ភារកសិកម្មផ្សេងទៀត ពុំត្រូវបានលើកទឹកចិត្តនៅក្នុងផលិតកម្មកសិកម្ម ប៉ុន្តែធាតុចូលទាំងនេះនៅតែត្រូវបានប្រើប្រាស់ដោយកសិករ និងធ្វើចរាចរលើទីផ្សារទូទាំងប្រទេស។ ជាការពិតណាស់យើងអាចចាត់ទុកថាការប្រើប្រាស់ថ្នាំកសិកម្ម ឬជីកសិកម្ម គឺអាចជាអាវុធមុខពីរ មានន័យថា ប្រសិនបើយើងប្រើប្រាស់បានត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេស និងចំទិសដៅនោះវានឹងអាចជួយការពារផលដំណាំពីការបំផ្លាញរបស់សមាសភាពចង្រៃ។ ប៉ុន្តែផ្ទុយមកវិញ ប្រសិនបើយើងប្រើប្រាស់វាមិនបានត្រឹមត្រូវទេនោះអាចបង្កឱ្យមានផលប៉ះពាល់អវិជ្ជមានជាច្រើន ដូចជាធ្វើឱ្យបាត់បង់តុល្យភាពជីវសាស្ត្រ ធ្វើឱ្យប៉ះពាល់ដល់សត្វមានប្រយោជន៍ និងសុខភាពមនុស្ស សត្វ ធ្វើឱ្យកខ្វក់ ឬបំពុលដល់បរិស្ថាន(ទឹក ដី និងបរិយាកាស) ជាឧបសគ្គដល់ការនាំផលិតផលកសិកម្មទៅលក់នៅក្រៅប្រទេស និងការអភិវឌ្ឍន៍វិស័យទេសចរណ៍ ។ល។ ជាការពិតណាស់ការប្រកួតប្រជែងជា មួយបណ្តាប្រទេសក្នុងតំបន់ ជាពិសេសដើម្បីរកទីផ្សារសម្រាប់ផលិតផលកសិកម្មនាពេលបច្ចុប្បន្ននេះគឺមានភាពតឹងតែងណាស់។ ដូច្នេះជម្រើសដ៏ល្អសម្រាប់កម្ពុជាគឺតម្រង់ទិសទៅរកផលិតផលកសិកម្មសរីរាង្គដែលមានសក្តានុពលទីផ្សារខ្ពស់ ហើយប្រជាកសិករមានលទ្ធភាពអាចធ្វើបាន និងមានលក្ខណៈសមស្របសម្រាប់លក្ខខណ្ឌនៃប្រទេសយើងផង។ បញ្ហាសំខាន់ កម្មវិធីផ្សព្វផ្សាយអប់រំដើម្បីតម្រង់ទិសឱ្យកសិករមានការយល់ដឹងនៅក្នុងការប្រើប្រាស់ជីកសិកម្ម ក៏ដូចជាសម្ភារកសិកម្មដែលធានាគុណភាព និងត្រឹមត្រូវតាមក្បួនខ្នាតបច្ចេកទេស គឺជាសកម្មភាពដ៏សមស្របមួយដែលឆ្លើយតបចំពោះអាទិភាពនៃគោលនយោបាយអភិវឌ្ឍវិស័យកសិកម្មរបស់រាជរដ្ឋាភិបាល ជាពិសេសគោលនយោបាយជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ។ ពិសេសជាងនេះទៅទៀតអាជីវករផ្គត់ផ្គង់ចែកចាយជីកសិកម្មគ្រប់រូបត្រូវមានវិចារញ្ញាណចូលរួមទាំងអស់

គ្មានទប់ស្កាត់ការយកប្រទេសកម្ពុជាធ្វើជាធុងសំ រាម សម្រាប់បោះចោល និងសាកល្បងសារធាតុគីមីកសិកម្មដែលផលិតដោយបច្ចេកវិទ្យាទំនើប ប៉ុន្តែមានហានិភ័យគ្រោះថ្នាក់ខ្ពស់ ដោយត្រូវលើកកម្ពស់សុខុមាលភាពសង្គម និងការពារផលប្រយោជន៍ប្រជាពលរដ្ឋកម្ពុជាទូទាំងប្រទេស និងសង្គមជាតិទាំងមូល ដែលត្រូវការស្បៀងគ្មានសារធាតុគីមីនិងស្បៀងមានសុវត្ថិភាពសម្រាប់ការលើកម្ពស់សុខភាពសាធារណៈ និងរក្សាបាននិរន្តរភាពនៃបរិស្ថាន។





## ឯកសារយោង

- អនុក្រឹត្យលេខ ៦៩ អនក្រ.បក ចុះថ្ងៃទី ២៨ ខែតុលា ឆ្នាំ ១៩៩៨ ស្តីពីបមាណីយ និងការគ្រប់គ្រងសម្ភារកសិកម្ម
- សារាចរណែនាំលេខ៣៤៥ សរណន.កសកចុះថ្ងៃទី ២១ ខែតុលា ឆ្នាំ ២០០២ ស្តីពីការអនុវត្តអនុក្រឹត្យលេខ ៦៩ អនក្រ.បក
- សេចក្តីព្រាងច្បាប់ស្តីពី"ការគ្រប់គ្រងថ្នាំកសិកម្ម និងជីកសិកម្ម"ខែមេសា ឆ្នាំ ២០១១
- របាយការណ៍អង្កេតអំពីជីគីមី និងថ្នាំកសិកម្ម ចុះបញ្ជិកាធ្វើអាជីវកម្ម និងប្រើប្រាស់ (ខេត្តកណ្តាល ឆ្នាំ២០០៩) គម្រោង QCAM/JICA-MAFF
- របាយការណ៍ការងារនីតិកម្មកសិកម្មប្រចាំឆ្នាំ(២០០៧-២០១០)
- របាយការណ៍សង្ខេបរបស់កម្មវិធីIPM ជាតិ ឆ្នាំ ១៩៩៣-២០០៩ អគ្គនាយកដ្ឋានកសិកម្ម (នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម)
- សេចក្តីណែនាំលេខ១៣៨៣ កសក ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០១០ ស្តីពីវិធានការពង្រឹងការត្រួតពិនិត្យគុណភាពសម្ភារកសិកម្ម
- ឯកសារគោលនយោបាយស្តីពីការជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ ឆ្នាំ ២០១០
- បណ្ឌិត ច័ន្ទ សារុន : កម្រងអត្ថបទស្រាវជ្រាវស្តីពី ការបង្កើនផលិតកម្ម និងពិពិធកម្មកសិកម្ម ២០១០
- បណ្ឌិត ហ៊ាន វណ្ណហន : ឯកសារជំនួយស្មារតីដើម្បីចូលរួមក្នុងពិធីជួបជុំភ្ញាក់ងារតំណាងចែកចាយជីប្រចាំឆ្នាំ ២០១០ របស់ក្រុមហ៊ុនយីតាក់ គ្រុប - មេសា ឆ្នាំ ២០១១
- នាយកដ្ឋាននីតិកម្ម កសិកម្ម : ជំនួយស្មារតីស្តីពីការគ្រប់គ្រងសម្ភារកសិកម្ម (គិតត្រឹមឆ្នាំ ២០១០) - មេសា ឆ្នាំ ២០១១